HOTEL CAMBODIANA

ភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

# កិច្ចព្រមព្រៀង

## ស្តីពី

## ការព្យួរកិច្ចសន្យាការងាររវាងនិយោជក

## និងនិយោជិតនៃសណ្ឋាគារកាំបូឌីយ៉ាណាក្រោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារ

## ជំងឺកូវិដ-១៩

ដោយបានឃើញអំពីទុកលំបាកដែលសណ្ឋាគារកាំបូឌីយ៉ាណា បាននិងកំពុងប្រឈមនាពេលបច្ចុប្បន្ន ដោយសារឥទ្ធិពលនៃការរីកសាយភាយជំងឺសកល កូវីដ-១៩ ដែលបានបណ្តាលឱ្យដំណើរការអាជីវកម្មរបស់សណ្ឋាគារបន្តជួបប្រទះនូវវិបត្តិយ៉ាងធ្ងន់ធ្ងរពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងនោះចំនួនភ្ញៀវស្នាក់នៅក្នុងសណ្ឋាគារបានបន្តធ្លាក់ចុះនៅឡើយ សិក្ខាសាលា កិច្ចប្រជុំនានា និងសេវាកម្មផ្សេងៗទៀតនៅតែបន្តធ្លាក់ចុះ គិតចាប់ពីពាក់កណ្តាល ខែមីនា ឆ្នាំ២០២០ មកទល់បច្ចុប្បន្ន។

ប្រឈមនិងបញ្ហានេះ និងដើម្បីបញ្ចៀសកុំឱ្យមានការផ្អាកដំណើរការអាជីវកម្មទាំងស្រុងរបស់សណ្ឋាគារ យើងខ្ញុំជានិយោជិតនៃសណ្ឋាគារកាំបូឌីយ៉ាណា យល់ព្រមទទួលយកការកំណត់ព្យួរកិច្ចសន្យាការងារបន្តរយៈពេល៦០ថ្ងៃទៀតដោយគ្មានប្រាក់ឈ្នួលនិងប្រាក់ឧបត្ថម្ភផ្សេងៗ តាមការកំណត់របស់សណ្ឋាគារ គិតចាប់ពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ រហូតទាល់តែទទួលបានការជូនដំណឹងជាថ្មី។

ដោយសារផ្នែកខ្លះនៃសណ្ឋាគារត្រូវបានផ្អាក និងខ្លះទៀតនៅមានប្រតិបត្តិការតិចតួចនៅឡើយ ហេតុដូច្នេះចំនួននិយោជិតដែលត្រូវបានព្យួរកិច្ចសន្យាការងារលើសពី ២១ថ្ងៃក្នុងមួយខែមានចំនួន១៩៧ នាក់។

ដើម្បីជាសក្ខីភាព យើងខ្ញុំទាំងអស់គ្នាសូមផ្តិតស្នាមម្រាមដៃ និងចុះហត្ថលេខារួមគ្នា។

រាជធានីភ្នំពេញថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០២០

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក



តំណាងនិយោជិត